**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

Ministry of Labour and Vocational Training

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥៣)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៣ ៩០៥ នាក់ នៃរោងចក្រ សហគ្រាស ទាំង២៣ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង២៣ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ២៣ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 12 |
| 1 | ក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ស៊ីនចាង ថេក អ៊ីន | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ហ៊ី ហ្សុង អ៊ីនធើប្រាយ ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហ្សាក់ស៊ីនតិច អ៊ីនដាស់ស្ទ្រីស៍ ខេមបូឌា ខូ អិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហ៊្សូ ឈុន ស៊ូ | ភ្នំពេញ |
| 6 | ក្រុមហ៊ុន អ៊ីអឹមប៊ី ផៃលក្ស៊ី (ខេមបូឌា)ខូ.,អិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន អេស.វ៉ាយ អ៊ីមប្រយឌើរី ឯ.ក | ភ្នំពេញ |
| 8 | ក្រុមហ៊ុន មរតកជាតិខ្មែរ អឹភើរីល លីមីធីត | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ញូ ហ្វូឌីស អីភែរីល (ខេមបូឌា) ឯ ក | កណ្តាល |
| 10 | ក្រុមហ៊ុន វីននីងជ្រាហ្គនឡេតជីរ៉េរ(ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 11 | ក្រុមហ៊ុន ហ៊ុង ស៊ីង ហ្គាម៉ិន (ខេមបូឌា) ឯ,ក_2 | តាកែវ |
| 12 | ក្រុមហ៊ុន ហ្គ្រេសហ្វូល(ខេបូឌា)ថេកស្ថាយ ខូ.អិលធីឌី | តាកែវ |
| ខ. វិស័យទេសចរណ៍ | | 11 |
| 13 | សណ្ឋាគារ រ៉ាហ្វិល រ៉ូយ៉ាល់ | ភ្នំពេញ |
| 14 | សណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ | ភ្នំពេញ |
| 15 | ក្រុមហ៊ុន អេឃ្សើ អេកស្ព័ឌីសិន (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 16 | ក្រុមហ៊ុន ថាឡាស | ភ្នំពេញ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 18 | ក្រុមហ៊ុន កូបេ យ៉ៃភែននីស រ៉េស្តូរ៉ែន | សៀមរាប |
| 19 | ក្រុមហ៊ុន ហ្វូខឺស អេស៊ា អ៊ីនធើណេសិនណលត្រាវែល សឺវីស | សៀមរាប |
| 20 | ក្រុមហ៊ុន ដឺ ប្លែក សាន់ រេសថឺរេន អេន បារ ខូ អិលធីឌី | សៀមរាប |
| 21 | ផ្ទះសំណាក់ ហនុមានាល័យ | សៀមរាប |
| 22 | ក្រុមហ៊ុន ភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 23 | ក្រុមហ៊ុន អេមព្រីស អង្គរ | សៀមរាប |